ទំព័រទី១៖ **ទស្សនាវដ្តី "និប៉ុនិកា" លេខ៣៨** ស្វែងយល់ពីប្រទេសជប៉ុន

# ជនជាតិជប៉ុន និងអវកាស

ទំព័រទី២៖

ទស្សនាវដ្តីលេខ៣៨នេះ និយាយអំពី «**ជនជាតិជប៉ុន និងអវកាស**»

តាំងពីបុរាណកាលមក ប្រជាជនជប៉ុនបានសញ្ជឹងគិតអំពីអាថ៌កំបាំងផ្នែកខាងក្រៅនៃពិភពលោក។ ស្វែងយល់ពីវប្បធម៌ដ៏គួរឱ្យចាប់អារម្មណ៍របស់ប្រទេសជប៉ុនស្តីពីអវកាស រួមមានចាប់តាំងពី រឿងនិទាន សិល្បៈ និងការកម្សាន្ត រហូតដល់ការរុករកអវកាស។

ទំព័រទី៣៖

មាតិកា

- បទពិសោធលំហអវកាសនៅប្រទេសជប៉ុន
- ទស្សនៈជប៉ុនចំពោះលំហអវកាស
- បច្ចេកវិទ្យាជប៉ុនរួមចំណែកដល់អវកាស
- មនុស្សបង្កើតលំហអវកាស
- អ្នកណាខ្លះចូលចិត្ត គំនូរជីវចលអវកាស(អានិមេអវកាស)?
- ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ ទីកន្លែងទាក់ទងនឹងអវកាសនៅទូទាំងប្រទេសជប៉ុន
- រសជាតិជប៉ុន៖ ពេលដែលត្រូវទទួលទាន! អាហារអវកាសជប៉ុន
- ដើរកំសាន្តប្រទេសជប៉ុន៖ កោះតាណិហ្គាស៊ីម៉ា
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ សម្ភារៈការិយាល័យបែបអវកាស

*រូបភាពខាងលើ៖ យានសាកល្បងរ៉ុក្កែត H3 លេខ 2 បានចាប់ផ្តើមបង្ហោះនៅឆ្នាំ២០២៤ (©JAXA)*
*រូបភាពលើគម្រប៖ ដើមសាគូរ៉ាងកោ នៅវាលណុហ៊ីរ៉ា ឈរនៅក្រោមមេឃពេលរាត្រី ដែលមានផ្កាយមីរដេរដាស នៅហ៉ាគុបាមុរ៉ា ខេត្តណាហ្គាណុ។ (រូបភាព៖Aflo)*

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំពីរភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង ព័រទុយហ្គាល់ រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្តី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*ទស្សនាវដ្ដីលេខ៣៨* R-070523
*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង* *https://www.mofa.go.jp/*

ទំព័រទី៤៖

## បទពិសោធលំហអាកាសនៅប្រទេសជប៉ុន

ជនជាតិជប៉ុនជាយូរយារណាស់មកហើយ តែងតែគោរពពន្លឺពីព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ ដែលបានឆ្លុះបញ្ចាំងពីភាពស្រស់ស្អាតទាំងនោះទៅក្នុងទេសភាព និងសិល្បៈរបស់ខ្លួន។ សម្រាប់ជនជាតិជប៉ុន ភាពអស្ចារ្យនៃលំហអាកាស តែងតែកើតពីការចុះសម្រុងគ្នារវាងធម្មជាតិ និងមនុស្សលោក។

ទំព័រទី៥៖

*ទិដ្ឋភាពអាចម៍ផ្កាយធ្លាក់នៅភ្នំហ្វូជិ។ (រូបភាព៖ PIXTA)*

ទំព័រទី៦៖

ទំព័រទី៧៖

រូបភាពនៅទំព័រទី៦ ផ្នែកខាងលើ៖ មេឃមានហ្វូងផ្កាយពីលើកន្លែងទីសក្ការៈកុនពីរ៉ា ក្នុងភូមិស្ស៊ូសានបិត្ស៊ុ នៅហុកកៃដូ (រូបភាព៖ PIXTA)
រូបភាពនៅទំព័រទី៧ ផ្នែកខាងលើ៖ «ជិត្ស៊ុហ្គិត្ស៊ុ អាគិគុសាហ្ស៊ុ ប្យ៉ូប៊ុ (ឡប្រឡៃ ឬរនាំងបត់ បានពណ៌នាអំពីព្រះចន្ទ និងព្រះអាទិត្យជាមួយនឹងស្មៅរដូវស្លឹកឈើជ្រុះ)»។ ស្នាដៃសិល្បៈដែលបង្ហាញពីគំនូរនេះ ដែលជាប្រធានបទដ៏ពេញនិយមនៃគំនូរជប៉ុនតាំងពីបុរាណមក តំណាងឱ្យវាលទំនាបមុសាស៊ីណុ នៅភាគខាងលិចទីក្រុងអេដុ(ទីក្រុងតូក្យូបច្ចុប្បន្ន)។ (ប្រមូលចងក្រងដោយ៖ សារមន្ទីរហ្វុជិតា)
រូបភាពនៅទំព័រទី៦ ផ្នែកខាងក្រោម៖ ព្រះអាទិត្យរះនៅចន្លោះម៉ិអុតុអ៊ីវ៉ា (ផ្ទាំងថ្មប្ដីប្រពន្ធ ឬ ដុំថ្មអាពាហ៍ពិពាហ៍) នៅហ្វុតាមិហ្គាអ៊ីរ៉ា ក្នុងទីក្រុងអ៊ិសិ ខេត្តមិអិ។ (រូបភាព៖ Adobe Stock)
រូបភាពនៅទំព័រទី៧ ផ្នែកខាងក្រោម៖ ចានតែ យ៉ូហិន តេនម៉ុគុ ជាទ្រព្យសម្បត្តិជាតិ ដែលគេជឿថាត្រូវបានធ្វើឡើងក្នុងសតវត្សរ៍ទី១២-១៣ គឺជាចានតែមួយក្នុងចំណោមបី ដែលមានវត្តមានរហូតមកដល់សព្វថ្ងៃនេះ។ បម្រែបម្រួលស្នាមរូបជានលើចានដូចហ្វូងផ្កាយដែលធ្វើឱ្យនឹកឃើញដល់អវកាស។ ត្រកូលអភិជននៅប្រទេសជប៉ុននាសម័យបុរាណ មានបំណងចង់ធ្វើជាម្ចាស់ចានតែពិសេសមួយក្នុងចំណោមចានតែពិសេសទាំងនេះ។ (ប្រមូលចងក្រងដោយ៖ សារមន្ទីរហ្វុជិតា

ទំព័រទី៨៖

*រូបខាងឆ្វេង៖ ព្រះនាង កាហ៊្គុយ៉ាហ៊ិមិ (ខាងលើស្តាំ) ចាកចេញពីផែនដី ដើម្បីត្រឡប់ទៅឋានព្រះចន្ទ ស្រង់ពីវគ្គមួយក្នុងរឿងអ្នកកាប់ឫស្សី។ (ប្រមូលចងក្រងដោយ៖ បណ្ណាល័យរដ្ឋសភាជាតិ)*
*រូបខាងក្រោម៖ ផែនទីតារាសាស្ត្រពីផ្នូរបុរាណគីតូរ៉ា រួមបញ្ចូលផ្កាយជាង៣៥០ដួង ព្រមទាំងរង្វង់ដែលត្រូវនឹង ខ្សែអេក្វាទ័រសេឡេស្ទាល និង អេគ្លីប (ផ្លូវនៃព្រះអាទិត្យ)។ (ផ្ទាំងគំនូរជញ្ជាំងចំនួន៥ ពីផ្នូរបុរាណគីតូរ៉ា ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃប្រទេសជប៉ុន។)*

## ទស្សនៈជប៉ុនចំពោះលំហអវកាស

តាំងពីបុរាណកាលមក ប្រជាជនជប៉ុនបានចាត់ទុកអវកាសជាផ្នែកបន្ថែមនៃធម្មជាតិ ហើយបានស្គាល់ និងស្និទ្ធស្នាលនឹងវា តាមរយៈរឿងនិទាន បទចម្រៀង និងកំណាព្យ។ វិធីសាស្ត្ររបស់ជប៉ុន ដើម្បីការអភិវឌ្ឍអវកាស ក៏បានឆ្លុះបញ្ចាំងពីទស្សនៈលំហអវកាសដ៏ពិសេសនេះផងដែរ។

### ឋានព្រះចន្ទដែលនៅជិតបង្កើយ

«តាកិតូរិ ម៉ូណុហ្គាតារិ (រឿងនិទានអ្នកកាប់ឫស្សី)» ដែលជាអក្សរសិល្ប៍និទានចំណាស់ជាងគេបំផុតរបស់ជប៉ុន ត្រូវបានសរសេរឡើងប្រហែលនៅសតវត្សរ៍ទី៩ ដែលមានលក្ខណៈពិសេសទាក់ទងនឹងព្រះចន្ទ។ នៅក្នុងរឿងនេះបង្ហាញពី ភាពអមតៈនៃឋានព្រះចន្ទ និងភាពមិនទៀងទាត់នៃពិភពផែនដី ដោយតួអង្គព្រះនាង កាហ៊្គុយ៉ាហ៊ិមិ ដែលចុះមកពីឋានព្រះចន្ទបានធំដឹងក្តីនៅលើផែនដី ហើយរួចគេចផុតពីការទាមទាររៀបអភិសេករបស់ស្តេចដែលលង់សម្រស់នាង ហើយក៏បានវិលត្រឡប់ទៅឋានព្រះចន្ទវិញ។ លើសពីនេះទៅទៀត ក្នុង «សាហ្គោរ៉ូម៉ុ ម៉ូណុហ្គាតារិ (រឿងនិទានសាហ្គោរ៉ូម៉ុ)» ដែលបង្កើតឡើងនៅសតវត្សរ៍ទី១១ ក៏មានវគ្គមួយដែលទេពធីតាមួយអង្គចុះពីឋានព្រះចន្ទ មកសួរសុខទុក្ខ លោក សាហ្គោរ៉ូម៉ុ ជូយ៉ូ ដែលកំពុងផ្តុំខ្លួយនៅមុខព្រះភ័ក្ត្រព្រះចៅអធិរាជ។ ចំណេះដឹងដែលយើងអាចទទួលបានពីរឿងនិទានទាំងពីរនេះ ដែលពណ៌នាអំពីអ្នកមកពីឋានព្រះចន្ទនោះ គឺជនជាតិជប៉ុនមានដែលអះអាងថា វត្ថុនៅលើមេឃ មិនមែនជារបស់ដែលនៅឆ្ងាយដាច់ស្រយាលនោះទេ តែជារបស់ដែលនៅជិតស្និទ្ធបំផុតជាមួយពិភពផែនដី។

### អវកាសជាផ្នែកបន្ថែមនៃធម្មជាតិ

ក្នុងសាសនា ស៊ីនតូ ដែលជាសាសនាបុរាណរបស់ជប៉ុន មានទស្សនៈមួយហៅថា «ទេពតាប្រាំបីលានអង្គ (យ៉ាអុយ៉ូរ៉ូហ្ស៊ុ ណុ កាមិ)» ដែលជឿថា មានទេពតាគង់នៅក្នុងវត្ថុគ្រប់យ៉ាង ដូចជា ភ្នំ សមុទ្រ ទន្លេ និងដើមឈើជាដើម។ សម្រាប់ជនជាតិជប៉ុនដែលប្រកបរបរកសិកម្មជាចម្បង ធម្មជាតិដែលបានផ្តល់ទាំងផលប្រយោជន៍ និងគ្រោះថ្នាក់ គឺជាវត្ថុដែលពួកគេមិនត្រឹមតែកោតខ្លាចប៉ុណ្ណោះទេ ថែមទាំងគោរពបូជាផងដែរ។ ហេតុនេះ វត្ថុនៅលើមេឃ ត្រូវបានចាត់ទុកជាទេពតាមួយអង្គក្នុងចំណោមទេពតាប្រាំបីលានអង្គ ដូចជាព្រះអាទិត្យត្រូវបានលើកឋានៈជាទេពតា «អាម៉ាតេរ៉ាស៊ុ អូមិកាមិ» ហើយព្រះចន្ទត្រូវបានលើកជាទេពតា «ត្សុគុយ៉ូមិ ណុ មិកុតុ»។ ទេពតាទាំងនេះជាអាទិទេពដ៏ខ្ពង់ខ្ពស់ ហើយក៏គេបានពណ៌នាថា ជាទេពតាដែលមានឥទ្ធិពលយ៉ាងធំធេង

ដល់ជីវិតមនុស្សលោក។ សរុបមក ទេពតានៅលើមេឃ តាមពិតមិនខុសពីទេពតានៅលើដីនោះទេ ដែលនាំឱ្យមានជំនឿថា អវកាស គឺជាផ្នែកបន្ថែមនៃធម្មជាតិ។

ដូច្នេះអំពីទស្សនៈអវកាសរបស់ជនជាតិជប៉ុនបែបនេះ ក៏បានបង្ហាញឡើងតាមរយៈបទចម្រៀង និងកំណាព្យផងដែរ។ ក្នុង «ម៉ាន់យ៉ូស្យ៊ូ» ដែលជាបណ្តុំកំណាព្យចាស់ជាងគេរបស់ជប៉ុន ដែលបានចងក្រងនៅសតវត្សរ៍ទី៧-៨ មានបទចម្រៀងលើកពីព្រះចន្ទមកនិពន្ធជាង១០០បទ។ ដូចជាការផ្ញើសេចក្តីក្នុងចិត្ត ទៅលើភ្នំ ទន្លេ និងរុក្ខជាតិ ហើយព្រះចន្ទ ក៏ត្រូវបានគេនិពន្ធក្នុងបទចម្រៀងដូចទៅនឹងធម្មជាតិដទៃទៀតដែរ។ លោក ម៉ាត្ស៊ុអុបាស្សូ ដែលជាកវី ហៃគុ (កំណាព្យជប៉ុន) ក្នុងសម័យអេដូ (១៦០៣–១៨៦៨) បាននិពន្ធឃ្លាហៃគុមួយថា «អារ៉ាយ៉ាមិ យ៉ា សាដុ និ យ៉ុកុតាហ្វុ អាម៉ា ណុ ហ្គាវ៉ា (សមុទ្រខឹងខ្លាំង និងផ្លូវហានសួគ៌(មីគីវ) លាតសន្ធឹងដល់កោះសាដុ)»។ ក្នុងឃ្លានេះ លោកបានរៀបរាប់ពីទិដ្ឋភាពដ៏ស្រស់ស្អាតដោយភ្ជាប់កោះសាដុ ដែលអណ្តែតលើសមុទ្រជប៉ុនដ៏កាចសាហាវ ជាមួយ ផ្លូវហានសួគ៌(មីគីវ) ដែលលាតសន្ធឹងនៅលើមេឃ។ តាមរយៈការដាក់ទិដ្ឋភាពនៃវត្ថុនៅលើមេឃ និងធម្មជាតិឱ្យនៅក្បែរគ្នា កំណាព្យនេះបានឆ្លុះបញ្ចាំងពីអារម្មណ៍របស់ជនជាតិជប៉ុន ដែលចាត់ទុកវត្ថុនៅលើមេឃ និងធម្មជាតិនៅលើផែនដី ជាអង្គតែមួយ។

<u>ទំព័រទី៩</u>៖

*រូបខាងលើ៖ ផ្លូវហានសួគ៌(មីគីវ) លាតសន្ធឹងលើផ្ទៃមេឃពីលើកោះសាដុ ដូចដែលបានពិពណ៌នានៅក្នុងកំណាព្យហៃគុ របស់លោក ម៉ាត្ស៊ុអុបាស្សូ។ (រូបថត៖Aflo)*
*រូបខាងលើកណ្តាល៖ កូណុតុរិ-១ ភ្ជាប់ខ្លួនទៅនឹង ស្ថានីយ៍អវកាសអន្តរជាតិ(ISS) ក្នុងបេសកកម្មផ្គត់ផ្គង់ឡើងវិញ។ (រូបថត៖JAXA/NASA)*
*រូបខាងលើស្តាំ៖ «ហ្វុហ្គាគុ ហ៊ុយ៉ាកេ ៖ តុរិហ្គោអិ ណុ ហ្វូជិ (ទិដ្ឋភាពមួយរយនៃភ្នំហ្វូជិ៖ ភ្នំហ្វូជិមើលពី តុរិហ្គោអិ)» ដែលជាផ្ទាំងគំនូរឈើ អ៊ុគិយ៉ុអិ បង្ហាញពី តារាវិថីអាសាគូសា (បង្កើតឡើងឆ្នាំ១៧៨២) ជាមួយនឹងឧបករណ៍វាស់ទីតាំងផ្កាយរាងស្វ៊ែរ ដាក់ទល់មុខនឹងទិដ្ឋភាពនៃភ្នំហ្វូជិ។ (ប្រមូលចងក្រងដោយ៖ បណ្ណាល័យរដ្ឋសភាជាតិ)*
*រូបខាងក្រោមស្តាំ៖ គីបូ គឺជា ម៉ូឌុល របស់ស្ថានីយអវកាសអន្តរជាតិ (ISS)។*

## ដំណើរនៃការស្រាវជ្រាវតារាសាស្ត្រនៅក្នុងប្រទេសជប៉ុន

ទោះជាយ៉ាងណាក៏ដោយ ជនជាតិជប៉ុនមិនមែនគ្រាន់តែស្រឡាញ់អវកាស ក្នុងន័យជា ធម្មជាតិ តែប៉ុណ្ណោះទេ នៅប្រហែលសតវត្សរ៍ទី៧ គេបានសាងសង់កន្លែងស្រាវជ្រាវតារាសាស្ត្រ ហើយបានទស្សន៍ទាយគ្រោះល្អ និងគ្រោះអាក្រក់ ពីបាតុភូតសូរ្យគ្រាស ចន្ទគ្រាស និងការលេចឡើងនៃផ្កាយដុះកន្ទុយ។ គេក៏បានបង្កើតប្រតិទិនដោយផ្អែកលើចលនារបស់ព្រះអាទិត្យ និងដំណើរពេញវង់នៃព្រះចន្ទផងដែរ។ នៅលើផ្ទាំងគំនូរជញ្ជាំងនៃ ផ្នូរបុរាណគីតុរ៉ា ដែលគេជឿថា គួរនៅចន្លោះចុងសតវត្សរ៍ទី៧ ដល់សតវត្សរ៍ទី៨ គឺមាននៅសល់ផែនទីតារាសាស្ត្រមួយក្នុងចំណោមផែនទីតារាសាស្ត្រចំណាស់ជាងគេបំផុតលើពិភពលោក។ នេះបង្ហាញឱ្យឃើញថា មនុស្សសម័យនោះបានស្រាវជ្រាវមើលវត្ថុនៅលើមេឃដោយមានចំណេះដឹងត្រឹមត្រូវ។ នៅសតវត្សរ៍ទី១៧ ចំណេះដឹងពីលោកខាងលិចបានហូរចូលមក ដែលជំរុញឱ្យការស្រាវជ្រាវរីកចម្រើនបន្ថែមទៀតដោយប្រើប្រាស់ កែវយឺត និងកុនតេនហ្គិ (ឧបករណ៍សម្រាប់ស្រាវជ្រាវតារាសាស្ត្រ) ហើយមូលដ្ឋានគ្រឹះនៃ តារាសាស្ត្រទំនើប ក៏ត្រូវបានបង្កើតឡើង។

## ឆ្ពោះទៅមុខរួមគ្នា និងចុះសម្រុងគ្នា ដើម្បីការអភិវឌ្ឍអវកាស

បច្ចុប្បន្ន ជប៉ុនគឺជាប្រទេសមួយក្នុងចំណោមប្រទេសជឿនលឿនផ្នែកអវកាស ដែលកំពុងដឹកនាំពិភពលោក តាមរយៈការបាញ់បង្ហោះរ៉ុក្កែត H3 ដែលបានបង្កើតឡើងដោយខ្លួនឯងដោយជោគជ័យ និងប្រតិបត្តិការផ្តាយរណបខ្នាតតូច។ លក្ខណៈពិសេស គឺប្រទេសជប៉ុនមិនត្រឹមតែចាត់ទុកការអភិវឌ្ឍបច្ចេកវិទ្យាជាការប្រកួតប្រជែងប៉ុណ្ណោះទេ តែបានផ្តោតសំខាន់លើការសហការជាមួយបណ្តាប្រទេសនានា ដើម្បីប្រើប្រាស់លំហអវកាសដោយសន្តិវិធី និងនិរន្តរភាព។

ជាឧទាហរណ៍ ក្នុងគម្រោងរួមគ្នាពហុជាតិសាសន៍«ស្ថានីយ៍អវកាសអន្តរជាតិ(ISS)»ដែលមានស្ថាប័នអន្តរជាតិចំនួន៥ចូលរួម។ ម៉ូឌុល[1] «គីបូ» ដែលត្រូវបានបង្កើតឡើងដោយប្រទេសជប៉ុនដើរតួយ៉ាងសំខាន់ជាមូលដ្ឋានស្រាវជ្រាវ និងទទួលខុសត្រូវចំពោះបេសកកម្មផ្គត់ផ្គង់យានជំនិះគ្មានមនុស្សបើក «កូណុតុរិ (HTV)» និងបានរួមចំណែកដល់មូលដ្ឋានគ្រឹះនៃគម្រោង ហើយទទួលបានការវាយតម្លៃខ្ពស់ពីប្រទេសជាច្រើន។

បន្ថែមពីនេះ គម្រោងរបស់ក្រុមហ៊ុនឯកជនដែលបច្ចុប្បន្នកំពុងព្យាយាមសម្អាតកំទេចកម្ទីអវកាស គឺជាតំណាងឱ្យកិច្ចខិតខំប្រឹងប្រែងរបស់ជប៉ុនដើម្បីរក្សាអវកាសជាទីកន្លែងដែលមាននិរន្តរភាព។ លើសពីនេះ ជប៉ុនក៏បានផ្តល់ជំនួយបច្ចេកទេសយ៉ាងសកម្មដល់ប្រទេសកំពុងអភិវឌ្ឍផ្នែកអវកាសផងដែរ។

ទស្សនៈអវកាសរបស់ជនជាតិជប៉ុន ដែលតាំងពីបុរាណកាលមក ចាត់ទុកអវកាសជាផ្នែកមួយនៃធម្មជាតិ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីជំហររបស់ជប៉ុន ចាត់ទុកថា អវកាសពុំមែនជាកន្លែងសម្រាប់ការតាំងទីលំនៅថ្មី និងអភិវឌ្ឍនោះទេ តែជា«ទីតាំងដែលផ្តល់ភាពចុះសម្រុងជាមួយមនុស្សក្នុងសកលលោក។

*ក្រោមការត្រួតពិនិត្យរបស់ លោក ហ្វុតាម៉ាសិ តុស៊ិហ្វុមិ*
*កើតនៅឆ្នាំ១៩៥៣។ ជាសាស្ត្រាចារ្យកិត្តិយស នៃសាកលវិទ្យាល័យ តុហុគុ ដែលជំនាញខាងរូបវិទ្យាតារាសាស្ត្រ។ ស្នាដៃនិពន្ធរបស់លោករួមមាន «និហុនជីន តុ អ៊ុជឺ (ជនជាតិជប៉ុន និងអវកាស)» និង«គិសុ ការ៉ា ម៉ាណាប៊ុ អ៊ុជឺ ណុ កាហ្គាគុះ ហ្គេនដៃ តេនម៉ុនហ្គាគុ អិណុ ស្សូតែ (ការរៀនវិទ្យាសាស្ត្រនៃអវកាសពីមូលដ្ឋានៈ ការអញ្ជើញចូលទៅកាន់តារាសាស្ត្រសម័យទំនើប)»*

[1] ម៉ូឌុល គឺជាសមាសធាតុដែលមានមុខងារឯករាជ្យដែលបង្កើតបានជាប្រព័ន្ធ ឬផលិតផលមួយ។

ទំព័រទី១០៖

## បច្ចេកវិទ្យាជប៉ុនរួមចំណែកដល់អវកាស

ការអភិវឌ្ឍបច្ចេកវិទ្យាអវកាសរបស់ជប៉ុន មានគោលបំណងរួមចំណែកដល់ការប្រើប្រាស់ដោយសន្តិភាពនូវលំហអវកាស ហើយវាបានបន្តរីកចម្រើន និងកំពុងដោះស្រាយបញ្ហាសកលដូចជា កំទេចកម្ទីសំណល់អវកាស និងបម្រែបម្រួលអាកាសធាតុ ផងដែរ។

### ផ្កាយរណបខ្នាតតូចប្រមូលទិន្នន័យជួយដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ និងបញ្ហាសកលនានា

ផ្កាយរណប SAR (Synthetic Aperture Radar: រ៉ាដាប្រហោងសំយោគ) ប្រើរលកមីក្រូវ៉េវដើម្បីស្រាវជ្រាវមើលផ្ទៃផែនដី។ ដោយសារវាមានសមត្ថភាពចាប់យករូបភាពចម្ងាយឆ្ងាយ វិសាលភាពធំទូលាយ និងមានកម្រិតបង្ហាញខ្ពស់ ដោយមិនថាអាកាសធាតុ ឬ ពេលវេលាណានោះទេ នាប៉ុន្មានឆ្នាំចុងក្រោយនេះ វាត្រូវបានគេប្រើប្រាស់ដើម្បីវាយតម្លៃទំហំនៃគ្រោះមហន្តរាយធម្មជាតិ និងវាស់វែងហានិភ័យនៃការបាក់ដី និងការប្រែប្រួលអាកាសធាតុ។

ក្នុងចំណោមនោះ ក្រុមហ៊ុន Synspective (ស៊ីនស្ពេកធីវ) បានបង្កើតបច្ចេកវិទ្យាផលិតទ្រង់ទ្រាយធំ ដើម្បីផលិតនូវផ្កាយរណប SAR ខ្នាតតូច ដែលមានទម្ងន់ស្រាលជាងផ្កាយរណបធំៗពីមុនប្រហែល១០ដង និងមានតម្លៃថោក។ ផ្កាយរណបនេះមិនងាយខូចនៅលើគន្លងគោចរឡើយ ដោយសារវាបំពាក់នូវអង់តែនបត់បាន ដែលមានប្រវែងវែងស្មើនឹងផ្កាយរណបធំៗ និងឧបករណ៍ពង្រីកកម្លាំងរ៉ាដា (amplifier) ទំហំ ១kw(គីឡូវ៉ាត់) ព្រមទាំងមានមុខងារបញ្ចាកម្តៅ ដ៏ល្អឥតខ្ចោះដើម្បីរក្សាសីតុណ្ហភាពដែលអាចទទួលយកបាន។

ក្រុមហ៊ុនកំពុងធ្វើការបង្កើតប្រព័ន្ធមួយដែលមានផ្កាយរណបជាច្រើន មានសមត្ថភាពអាចស្រាវជ្រាវមើលផែនដីទាំងមូលបានក្នុងពេលវេលាជាក់ស្តែង(quasi-real-time) តាមរយៈការបង្កើត Satellite Constellation (ប្រព័ន្ធដែលបញ្ជូនផ្កាយរណបសិប្បនិម្មិតច្រើនទៅក្នុងគន្លងគោចរតែមួយ ហើយធ្វើការរួមគ្នាដើម្បីផ្តល់ទំនាក់ទំនង ឬ ការស្រាវជ្រាវក្នុងវិសាលភាពធំទូលាយក្នុងពេលតែមួយ)។ ក្រុមហ៊ុនមានកំណត់ត្រាផ្តល់ទិន្នន័យការខូចខាតពីការរញ្ជួយដី និងទឹកជំនន់ដល់រដ្ឋាភិបាលក្នុងប្រទេសជប៉ុន ហើយថែមទាំងបានព្យាករណ៍ពីការខូចខាតដោយសារការបាក់ដីជាច្រើននៅបរទេសផងដែរ។ ក្រុមហ៊ុនគ្រោងនឹងពង្រីកទៅកាន់ទ្វីបអាស៊ី និងអាមេរិកខាងជើង ហើយនឹងព្យាយាមដោះស្រាយបញ្ហាពិសេសៗដែលកើតមានក្នុងតំបន់ទាំងនោះ។

*១. StriX គឺជាផ្កាយរណប SAR (Synthetic Aperture Radar) ខ្នាតតូច មានទម្ងន់ប្រហែល ១០០គីឡូក្រាម ដែលមានទំហំប្រហែល ១/១០ នៃផ្កាយរណបធំៗ។ នៅពាក់កណ្តាលចុងក្រោយនៃទសវត្សរ៍ឆ្នាំ២០២០ ផ្កាយរណប SAR ចំនួន៣០នេះនឹងបង្កើតជា ក្រុមផ្កាយរណប (constellation)។*

*២. រូបភាពក្រាហ្វិកកុំព្យូទ័របង្ហាញពីផ្កាយរណប SAR ខ្នាតតូចកំពុងកត់ត្រាទិន្នន័យ។ ផ្កាយរណបនេះបញ្ជូនរលកមីក្រូវ៉េវ (microwaves) បន្ទាប់មកទទួលរលកមីក្រូវ៉េវដែលឆ្លុះត្រឡប់មកពីផ្ទៃផែនដីវិញ។ រលកមីក្រូវ៉េវអាចជ្រាបចូលតាមរយៈពពកបាន ធ្វើឱ្យវាអាចកត់ត្រាទិន្នន័យបានគ្រប់លក្ខខណ្ឌអាកាសធាតុ ទាំងថ្ងៃទាំងយប់។*

*៣. អ្នកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន Synspective Inc. (ខាងឆ្វេង) នៅក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ជាមួយប្រទេសកាហ្សាក់ស្ថាន ស្តីពីការប្រើប្រាស់ផ្កាយរណប SAR ខ្នាតតូចដើម្បីបង្ការគ្រោះមហន្តរាយ។ (រូបថត៖ Synspective Inc.)*

<u>ទំព័រទី១១៖</u>

*១. រូបភាពក្រាហ្វិកកុំព្យូទ័រ បង្ហាញពីផ្កាយរណប ADRAS-J កំពុងទៅជិតកំទេចកម្ទីកាកសំណល់ (debris) (ខាងស្តាំ) សម្រាប់ការស្រាវជ្រាវពីចម្ងាយជិត។*
*២. ADRAS-J នៅពេលនៃការអភិវឌ្ឍ។ (រូបថត៖ Astroscale Inc.)*

## ការរៀបចំប្រតិបត្តិការសម្អាតអវកាស

កំទេចកម្ទីអវកាស (Space debris) ដែលរួមមានដូចជា ផ្កាយរណបអស់មុខងារ និងបំណែករ៉ុក្កែត ត្រូវបានគេប៉ាន់ស្មានថាមានជាង ១០០ លានបំណែក នៅក្នុងគន្លងគោចរជុំវិញផែនដី ហើយប្រសិនបើវាប៉ះទង្គិចជាមួយផ្កាយរណប ឬ ស្ថានីយអវកាស វាអាចបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ក្រុមហ៊ុន Astroscale Inc. គឺមានបេសកកម្មដ៏កម្រមួយដែលជាកិច្ចប្រឹងប្រែងជាសកលដើម្បីសម្អាតកំទេចកម្ទីទាំងនេះចេញ ដែលជាឧបសគ្គដល់ការអភិវឌ្ឍអវកាស។ ផ្កាយរណបADRAS-J ដែលត្រូវបានបាញ់បង្ហោះនៅឆ្នាំ២០២៤ បានជោគជ័យក្នុងការចូលទៅជិតកំទេចកម្ទីអវកាសដែលធ្វើដំណើរក្នុងល្បឿនលឿនបំផុត ៧-៨ គីឡូម៉ែត្រ/វិនាទីដោយសុវត្ថិភាព។ ពីដំបូងឡើយ វាមានគម្លាតពីគ្នារាប់ពាន់គីឡូម៉ែត្រ ប៉ុន្តែវាបានទទួលជោគជ័យក្នុងការកាត់បន្ថយចម្ងាយនោះមកត្រឹម១៥ម៉ែត្រ។ ក្នុងចំណោមសមិទ្ធផលផ្សេងទៀត ក្រុមហ៊ុន Astroscale កំពុងបន្តអភិវឌ្ឍផ្កាយរណប ADRAS-J2 ដែលជាផ្កាយរណបមានសមត្ថភាពអាចសម្អាតកំទេចកម្ទីអវកាសដែលមានទំហំធំរហូតដល់១១ម៉ែត្របាន។

## ការជំរុញការអភិវឌ្ឍអវកាស និងការបណ្តុះបណ្តាលធនធានមនុស្សនៅអាស៊ី

សាកលវិទ្យាល័យហុកកៃដូ ដែលមានទីតាំងនៅតំបន់ភាគខាងជើងនៃប្រទេសជប៉ុន គឺជាសាកលវិទ្យាល័យដ៏កម្រមួយក្នុងពិភពលោក ដែលមានអ្នកស្រាវជ្រាវមកពីដេប៉ាតឺម៉ង់វិស្វកម្ម (ដែលផ្តោតលើការអភិវឌ្ឍរ៉ុក្កែត និងឧបករណ៍ផ្សេងៗ) បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ អ្នកស្រាវជ្រាវនៅក្នុងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ (ដែលអភិវឌ្ឍឧបករណ៍អុបទិកសម្រាប់បំពាក់លើផ្កាយរណប) និងអ្នកស្រាវជ្រាវនៅដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្ម និងជលផល (ដែលវិភាគទិន្នន័យពីផ្កាយរណប និងយានអវកាស)។ ក្នុងសាកលវិទ្យាល័យ មានមជ្ឈមណ្ឌលបេសកកម្មអវកាស ដែលជាផ្នែកមួយនៃវិទ្យាស្ថាននវានុវត្តន៍របស់សាកលវិទ្យាល័យហុកកៃដូ ដែលធ្វើការលើបេសកកម្មអវកាសផ្សេងៗ ដោយសហការជាមួយក្រុមហ៊ុនឯកជន និងសាកលវិទ្យាល័យជិតខាង។ មជ្ឈមណ្ឌលនេះបានអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗដូចជា ប្រព័ន្ធម៉ាស៊ីនសម្រាប់ផ្កាយរណបខ្នាតតូច និងផ្កាយរណបណាណូទម្ងន់ ៥០គីឡូក្រាម។

ចាប់ពីឆ្នាំ២០១៥មក មជ្ឈមណ្ឌលបេសកកម្មអវកាសនេះ បានសហការជាមួយប្រទេសហ្វីលីពីន ដើម្បីបង្កើតផ្កាយរណបដំបូងបំផុតរបស់ប្រទេសនោះ ដែលបាននាំទៅដល់ការបង្កើតទីភ្នាក់ងារអវកាសហ្វីលីពីន (PhilSA)។ កិច្ចខិតខំប្រឹងប្រែងនេះបានពង្រីកវិសាលភាពដល់ប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀត ហើយ «សម្ព័ន្ធផ្កាយរណបខ្នាតតូចអាស៊ី» ដែលមានប្រទេសអាស៊ី៩ចូលរួម ត្រូវបានដឹកនាំដោយសាកលវិទ្យាល័យហុកកៃដូ និងសាកលវិទ្យាល័យតូហុគុ។ ទីស្នាក់ការកណ្តាលនៃបណ្តាញអភិវឌ្ឍន៍អវកាសអាស៊ីកំពុងត្រូវបានបង្កើតឡើងនៅលើទឹកដីភាគខាងជើងនៃប្រទេសជប៉ុន។

*១. ម៉ូទ័រទាត់កូនកាត់ (Hybrid Kick Motor) សម្រាប់ផ្កាយរណបខ្នាតតូចដែលបង្កើតឡើងដោយ មន្ទីរពិសោធន៍ប្រើប្រាស់លំហអវកាស នៃសាកលវិទ្យាល័យហុកកៃដូ គឺមានប្រយោជន៍ក្នុងការបាញ់បង្ហោះផ្កាយរណបខ្នាតតូចច្រើនក្នុងរ៉ុក្កែតតែមួយ ដែលត្រូវបានដាក់ចូលទៅក្នុងគន្លងគោចរៀងៗខ្លួនដែលបានកំណត់។ (រូបថត៖ មន្ទីរពិសោធន៍ប្រើប្រាស់លំហអវកាសនៃសាកលវិទ្យាល័យហុកកៃដូ)*
*២. មន្ទីរពិសោធន៍ សម្រាប់អ្នកស្រាវជ្រាវវ័យក្មេងមកពីប្រទេសនានានៅអាស៊ីអាគ្នេយ៍។*

<u>ទំព័រទី១២</u>៖

## មនុស្សបង្កើតលំហអវកាស

### អ្នកបង្កើតលំហវិថីតារាសិប្បនិម្មិតដែលមានផ្ទៃមេឃពោរពេញដោយផ្កាយ

លំហវិថីតារាសិប្បនិម្មិត (Planetarium) គឺជាកន្លែងដែលបង្ហាញផ្ទៃមេឃពេលយប់ដោយបញ្ចាំងរូបភាពផ្កាយទៅលើអេក្រង់ពិដានរាងក្រឡូម។ លំហវិថីតារាសិប្បនិម្មិតអុបទិក(optical planetarium) ដែលមានសមត្ថភាពបញ្ចាំងរូបភាពផ្កាយក្នុងកម្រិតច្បាស់ ដោយប្រើបន្ទះរូបភាពផ្កាយ និងកញ្ចក់លែន គឺប្រើប្រាស់ម៉ាស៊ីនបញ្ចាំងថ្មី ប្រកបដោយភាពច្នៃប្រឌិត ហើយអ្នកបង្កើតលំហវិថីតារាសិប្បនិម្មិតនេះគឺ លោក អូហ៊ីរ៉ា តាកាយុគិ។

នៅឆ្នាំ១៩៩៨ លោក អូហ៊ីរ៉ា បានប្រកាសដាក់ឱ្យប្រើប្រាស់នូវ «MEGASTAR» ដែលអាចបញ្ចាំងរូបភាពផ្កាយ ចំនួន ១៧០ម៉ឺនដួង ដែលស្មើនឹងច្រើនជាង ១០០ដង នៃឧបករណ៍ធម្មតា។ លោកបានទទួលជោគជ័យក្នុងការបញ្ចាំងផ្កាយរាប់មិនអស់នៅគន្លងដួងតារាមីគីវេ ដែលបានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើល។ បន្ទាប់មក លោកបានបន្តកែប្រែម៉ូដែលបន្តបន្ទាប់ដើម្បីបង្កើនចំនួនផ្កាយដែលត្រូវបានបញ្ចាំង។ លើសពីនេះ នៅឆ្នាំ២០១៥ លោកបានបង្កើតបន្ទះផ្កាយថេរ ដែលមានភាពជាក់លាក់ខ្ពស់បំផុត «GIGAMASK» ដែលអាចបញ្ចាំងផ្កាយបានដល់ទៅ ១២០លានដួង។ រន្ធតូចបំផុតដែលត្រូវបានខួងនៅលើបន្ទះផ្កាយថេរនោះមានទំហំតូចបំផុតត្រឹមតែមានអង្កត់ផ្ចិត ១៨០ nm (ណាណូម៉ែត្រ) ឬ ១៨/១០ម៉ឺនmm (មីលីម៉ែត្រ) ប៉ុណ្ណោះ។

លោក អូហ៊ីរ៉ា មានប្រសាសន៍ថា៖ «ផ្កាយដែលភ្នែកមនុស្សអាចមើលឃើញនៅលើផ្ទៃមេឃពេលយប់ គឺមានតែមួយផ្នែកតូចប៉ុណ្ណោះ ប៉ុន្តែតាមពិតទៅ មានផ្កាយរាប់មិនអស់កំពុងភ្លឺចែងចាំងនៅក្នុងលំហអវកាស។ ដូច្នោះហើយ យើងអាចមើលឃើញវាបាននៅក្នុងលំហវិថីតារាសប្បនិម្មិត។ ខ្ញុំចង់ឱ្យមនុស្សមានអារម្មណ៍ថាលំហអវកាសមានភាពធំធេងគ្មានដែនកំណត់តាមរយៈវិធីនេះ»។

លោក អូហ៊ីរ៉ា ក៏បានបង្កើតឧបករណ៍លំហវិថីតារាសិប្បនិម្មិតអុបទិកសម្រាប់ប្រើប្រាស់ក្នុងផ្ទះឈ្មោះ «HOMESTAR» ដែលបានប្រើបច្ចេកវិទ្យា «MEGASTAR» ផងដែរ។ វាកំពុងទទួលបានប្រជាប្រិយភាពនៅក្នុងប្រទេសជាច្រើនដោយសារមនុស្សអាចរីករាយជាមួយផ្ទៃមេឃពោរពេញដោយផ្កាយនៅផ្ទះបានយ៉ាងងាយស្រួល។ លោកបានបន្ថែមថា៖ «ខ្ញុំសង្ឃឹមថាកុមារកាន់តែច្រើននឹងចាប់អារម្មណ៍លើលំហអវកាសតាមរយៈលំហវិថីតារាសិប្បនិម្មិត។ ខ្ញុំនឹងរីករាយប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមពួកគេអាចចេញទៅកាន់លំហអវកាស ហើយរកឃើញជីវិតដែលមិនទាន់ស្គាល់នៅថ្ងៃអនាគត»។

*១. លោកអូហ៊ីរ៉ា កំពុងកាន់ម៉ាស៊ីនបញ្ចាំងលំហរវិថីតារាសិប្បនិម្មិតខ្នាតតូចចុងក្រោយបង្អស់គឺ MEGASTAR-Neo II។*
*២. បន្ទះរូបភាពផ្កាយ GIGAMASK មួយក្នុងចំណោមបន្ទះរូបភាពផ្កាយជាច្រើន។ ម៉ាស៊ីនបញ្ចាំងប្រើបន្ទះទាំង ៣២ ផ្ទាំងដើម្បីបញ្ចាំងផ្កាយប្រហែល ១២០លានដួង ដោយបន្ទះនីមួយៗ បង្កើតផ្កាយប្រមាណ ២០០-៣០០ លានដួង ក្នុងតំបន់ដែលមានផ្កាយច្រើន។*
*៣. ស៊េរី HOMESTAR ជាម៉ាស៊ីនបញ្ចាំងលំហរវិថីតារាអុបទិកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ។ មុខងារភ្លើបភ្លែតៗ ដែលបានបន្ថែមនៅឆ្នាំ២០២១ ផ្តល់ឱ្យអ្នកប្រើប្រាស់នូវផ្ទៃមេឃពេលយប់ដែលមានផ្កាយកាន់តែពិតៗនៅផ្ទះ។*

<u>ទំព័រទី១៣៖</u>

ទម្រង់ថ្មីនានានៃលំហអវកាស ដែលបង្កើតឡើងដោយការប្រកួតប្រជែងរបស់វិស្វករជប៉ុន តាមរយៈការបង្កើតឡើងវិញនូវផ្ទៃមេឃពោរពេញដោយផ្កាយ និងការបង្កើតផ្កាយដុះកន្ទុយសិប្បនិម្មិត។

*រូបថត៖ ហ្វូសោតុ ម៉ាអ៊ិ*

## ការប្រកួតប្រជែងដំបូងបំផុតលើពិភពលោក៖ ការបង្កើតផ្កាយដុះកន្ទុយសិប្បនិម្មិត

លោកស្រី អូកាជីម៉ា រ៉េណា នាយិកាក្រុមហ៊ុន ALE (អេល) កំពុងសាកល្បងនឹងអាជីវកម្មមួយដំបូងគេនៅលើពិភពលោក។ ការសាកល្បងនេះ វាចាប់ផ្តើមពីគំនិតដែលកើតឡើងពេលលោកស្រីពេលនៅជានិស្សិតសាកលវិទ្យាល័យ នៅពេលឃើញផ្កាយដុះកន្ទុយលីអូនីត (Leonid meteor shower)៖ «ខ្ញុំចង់បង្កើតផ្កាយដុះកន្ទុយសិប្បនិម្មិតនៅត្រង់កន្លែង និងពេលវេលាដែលយើងចង់ឃើញវា»។

ជាតុសំខាន់នៃផ្កាយដុះកន្ទុយសិប្បនិម្មិត គឺជាគ្រាប់លោហៈមានអង្កត់ផ្ចិតប្រហែល ១ cm (សង់ទីម៉ែត្រ) ដែលហៅថា «ភាគល្អិតអាចម៍ផ្កាយ (meteor particles)»។ នៅពេលបញ្ចេញពីផ្កាយរណប ភាគល្អិតអាចម៍ផ្កាយទាំងនេះធ្លាក់មកកាន់ផែនដី ហើយឆេះអស់នៅសីតុណ្ហភាពខ្ពស់ដោយសារការបង្ហាប់ដោយកម្តៅគ្មានការផ្លាស់ប្តូរកម្តៅ នៅពេលពួកវាចូលក្នុងបរិយាកាសផែនដី។ មើលពីដីទៅ ភាគល្អិតដែលធ្លាក់ទាំងនេះមើលទៅដូចជាផ្កាយដុះកន្ទុយ។ លោកស្រីបានពន្យល់ថា៖ «គោលការណ៍នេះ គឺដូចគ្នានឹងផ្កាយដុះកន្ទុយពិតៗ ដែលយើងស្រាវជ្រាវមើលធូលីអវកាសឆេះក្នុងបរិយាកាសដែរ។ ប៉ុន្តែផ្កាយដុះកន្ទុយដែលយើងបង្កើត គឺភ្លឺជាង រហូតដល់អាចមើលឃើញយ៉ាងច្បាស់ក្នុងផ្ទៃមេឃក្នុងទីក្រុង ហើយក៏អាចមើលឃើញបានយូរជាងមុនដែរ»។ បច្ចុប្បន្ន វាត្រូវបានគេរំពឹងថា នឹងមានការប្រើប្រាស់ជាច្រើននាពេលអនាគត រួមទាំងជាទម្រង់ការកម្សាន្តថ្មីដែលនឹងលម្អផ្ទៃមេឃជាមួយពណ៌ចម្រុះ។ ក្រៅពីនេះ ការប្រមូលទិន្នន័យបរិយាកាសដែលប្រមូលបានក្នុងពេលបញ្ចេញផ្កាយដុះកន្ទុយសិប្បនិម្មិត ក៏ត្រូវបានគេរំពឹងថានឹងជួយដល់ការវិភាគបម្រែបម្រួលអាកាសធាតុផងដែរ។

អនាគតដែលលោកស្រី អូកាជិម៉ា ចង់មើលឃើញ គឺពិតជាធំធេង ហើយត្រចះត្រចង់ ដែលលោកស្រីមានប្រសាសន៍ថា៖ «ខ្ញុំចង់ធ្វើឱ្យអវកាសក្លាយជាតំបន់វប្បធម៌»។

*១. លោកស្រី អុកាជីម៉ា ថតជាមួយនឹងគំរូនៃផ្កាយរណបដែលបាញ់បង្ហោះដោយក្រុមហ៊ុន ALE។*
*២. លោកស្រី អុកាជីម៉ា ពិសោធន៍មុខងារផ្កាយរណប។ ប្រតិបត្តិការផ្កាយរណប និងការផ្គត់ផ្គង់ថាមពលត្រូវបានគ្រប់គ្រងដោយការណែនាំពីក្រុមការងារនៅលើដី។*
*៣. ផ្កាយរណបត្រូវបានបំពាក់ដោយសមាសធាតុប្រព័ន្ធបេសកកម្ម និងផ្នែកដែលបញ្ចេញភាគល្អិតអាចម៍ផ្កាយ (រូបថតខាងលើ)។*
*៤. ការបង្ហាញសិល្បៈ នៃផ្កាយដុះកន្ទុយធ្លាក់ចុះ ដែលបង្កើតដោយមនុស្ស។*

<u>ទំព័រទី១៤៖</u>

## អ្នកណាខ្លះចូលចិត្ត គំនូរជីវចលអវកាស(អានិមេអវកាស)?

គំនូរជីវចលអវកាសរបស់ជប៉ុនបង្ហាញតួអង្គជាច្រើននៅក្នុងឆាកអវកាសដ៏ធំធេង។ សូមស្វែងយល់ពីស្នាដៃដែលបានផ្តល់ក្តីសុបិន និងការស្រមៃចង់បានលំហអវកាសដល់កុមារ។

### អ៊ុជឹក្យូដៃ (បងប្អូនលំហអវកាស)

រឿងនេះបង្ហាញពីការតស៊ូរបស់បងប្រុសឈ្មោះ ណានបា មូតតា ដែលចាប់ផ្តើមមានមហិច្ឆតាក្លាយជាអវកាសយានិកនៅអាយុជាង ៣០ឆ្នាំ និងប្អូនប្រុសឈ្មោះ ហ៊ីប៊ីតុ ដែលបានសម្រេចក្តីសុបិនមុនហើយបានចុះចតលើឋានព្រះចន្ទ។ គំនូរជីវចលនេះផ្តោតលើទាំងការខិតខំ និងការបរាជ័យរបស់អ្នកទាំងពីរព្រមទាំងការតស៊ូរបស់មិត្តភក្តិរបស់ពួកគេដែលប្រឈមមុខនឹងលំហអវកាស។ ស្ថាប័នអភិវឌ្ឍន៍អវកាសពិតប្រាកដដូចជា ទីភ្នាក់ងាររុករកអវកាសជប៉ុន (JAXA) ក៏លេចឡើងផងដែរ ហើយវាពិពណ៌នាយ៉ាងលម្អិតអំពីស្ថានភាពអភិវឌ្ឍន៍អវកាសជាក់ស្តែងនាពេលបច្ចុប្បន្ន។ ស្នាដៃនេះមានអ្នកគាំទ្រជាច្រើនក្នុងចំណោមអ្នកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអវកាស។

*© Koyama Chuya/ Kodansha Ltd./ YOMIURI TELECASTING CORPORATION/ A-1 pictures*

### អ៊ុជឹណានចារ៉ា កុតិត្ស៊ុគុន (អវកាស កុតិត្ស៊ុគុន)

រឿងនេះបង្ហាញពី "កុតេត្ស៊ឹគុន" ដែលបានចូលរៀននៅ "សាលាបណ្តុះបណ្តាលអវកាស" ដោយមានគោលបំណងក្លាយជាអវកាសយានិក ព្រមទាំងរៀនជាមួយមិត្តភក្តិដែលមានក្តីសុបិនប្លែកៗដូចជា អ្នកអភិវឌ្ឍន៍រ៉ុក្កែត និងចុងភៅអាហារអវកាស។ ខណៈពេលដែលរីករាយជាមួយការលេងសើចកំប្លែងរបស់តួអង្គដែលមានបុគ្គលិកលក្ខណៈផ្សេងៗ គំនូរជីវចលនេះក៏ឆ្លើយសំណួរដ៏សាមញ្ញ ដោយងាយស្រួលយល់ដូចជា "តើលំហអវកាសកើតឡើងដោយរបៀបណា?" ឬ "តើមានក្លិននៅក្នុងលំហអវកាសដែរឬទេ?"។

*© Space Academy/ Chokkura Tukimade Iinkai 2*

ទំព័រទី១៥៖

## ហ្គីនហ្គាតិត្សឹដូ ស្រ៊ីណាញ (រថភ្លើងកាឡាក់ស៊ី៩៩៩)

ជាស្នាដៃបែបវិទ្យាសាស្ត្រប្រឌិត(SF) ដែលផលិតនៅឆ្នាំ១៩៧៨-១៩៨១ ដោយផ្អែកលើរឿងម៉ានហ្គា របស់លោក ម៉ាត្ស៊ុមុតុ រ៉េជិ។ រឿងនេះពណ៌នាពីដំណើរផ្សងព្រេងរបស់ក្មេងប្រុសម្នាក់ឈ្មោះ ហុស៊ិណុ តេត្ស៊ុរ៉ុ ដែលជិះរថភ្លើងអវកាសលេខ ៩៩៩ ជាមួយនឹងនារីអាថ៌កំបាំងម្នាក់ឈ្មោះ ម៉េតែល ដើម្បីស្វែងរករូបកាយដែលអាចទទួលបានជីវិតអមតៈ។ តាមរយៈទំនាក់ទំនងជាមួយមនុស្ស និងការរស់ដែលជួបនៅតាមភពជាចំណតនៃរថភ្លើង ស្នាដៃនេះបង្ហាញពីភាពល្ងង់ខ្លៅ និងភាពទន់ខ្សោយរបស់មនុស្ស ព្រមទាំងតម្លៃនៃជីវិត។ រូបភាពរថភ្លើងលេខ៩៩៩ ដែលយកគំរូតាមក្បាលរថភ្លើងចំហាយទឹកពិតប្រាកដ បន្លឺសំឡេងស៊ីផ្លេរបស់វា ហើយរត់ឆ្លងកាត់កាឡាក់ស៊ី បានទាក់ទាញមនុស្សជាច្រើន។

*© Matsumoto Leiji/ Leiisha/ TOEI ANIMATION CO., LTD.*

## ឈិក្យូហ្គៃស្ស៊ូណែនស្សូយ៉ុ (ក្មេងស្រីក្មេងប្រុសនៅក្រៅភពផែនដី)

ស្នាដៃនេះមានឆាកបង្ហាញនៅឆ្នាំ២០៤៥ ជាពេលដែលការធ្វើដំណើរទៅអវកាសបានក្លាយជារឿងធម្មតា។ ក្មេងៗប្រាំនាក់ដែលជាប់នៅក្នុងសណ្ឋាគារអវកាសដោយសារគ្រោះថ្នាក់ធំមួយ បានតស៊ូជំនះឧបសគ្គជាច្រើនដែលកើតមានជាបន្តបន្ទាប់ ដើម្បីគេចចេញដោយខ្លួនឯង។ ខណៈពេលដែលបង្ហាញពីស្ថានភាពគ្រោះថ្នាក់ដ៏ខ្លាំងបំផុតក្នុងបរិយាកាសនៃលំហអវកាសដោយភាពតានតឹង រឿងនេះក៏ពណ៌នាយ៉ាងរស់រវើកអំពីមនុស្សដែលរស់នៅក្នុងលំហអវកាស មានហាងលក់ទំនិញ និងអ៊ីនធឺណិត ព្រមទាំងការរស់នៅជាមួយ បញ្ញាសិប្បនិមិត្ត (AI) ដែលត្រូវបានបង្ហាញជាទស្សនៈអនាគតប្រកបដោយភាពប្រាកដនិយម។

*© MITSUO ISO/ avex pictures/ The Orbital Children Production Committee (គណៈកម្មាធិការឈិក្យូហ្គៃស្ស៊ូណែនស្សូយ៉ុ)*

ទំព័រទី១៦៖

## ខេត្តតុតតុរិ «ភ្នំដៃសេន»

តំបន់នេះត្រូវបានគេស្គាល់ថាជា «ខេត្តមើលផ្កាយ» ព្រោះខេត្តតុតតុរិ ទាំងមូលមានទិដ្ឋភាពមេឃដែលពោរពេញដោយផ្កាយយ៉ាងស្រស់ស្អាត។ ភ្នំដៃសេន ដែលមានកម្ពស់១៧២៩ម៉ែត្រ នៅភាគខាងលិចនៃខេត្ត ផ្តល់ជូននូវការមើលផ្កាយដ៏អស្ចារ្យជាពិសេស។ សូមថតរូបជាអនុស្សាវរីយ៍នៅពីមុខផ្ទៃមេឃដែលពោរពេញដោយផ្កាយ ដែលវាមានការប្រែប្រួលជារៀងរាល់ម៉ោង ឬរដូវ ឬសូម្បីកាឡាក់ស៊ីមីគីវេ ក៏មើលឃើញយ៉ាងច្បាស់ដោយភ្នែកទទេដែរ។ *(រូបថត៖ «ដំណើរកម្សាន្តថតរូបមេឃដែលមានផ្កាយ» ឧបត្ថម្ភដោយការិយាល័យទេសចរណ៍ដៃសេន)*

## ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ ទីកន្លែងទាក់ទងនឹងអវកាសនៅទូទាំងប្រទេសជប៉ុន

សូមទស្សនាផ្ទៃមេឃដែលពោរពេញដោយផ្កាយដ៏គួរឱ្យចាប់អារម្មណ៍ ឬ ទទួលបានបទពិសោធន៍ក្នុងលំហដែលអវកាសយានិកពិតប្រាកដជួបប្រទះ។ ទីកន្លែងនានាទូទាំងប្រទេសជប៉ុននៃអវកាសដែលលាតសន្ធឹងដ៏ឆ្ងាយនឹងអាចឱ្យអ្នកមានអារម្មណ៍ថាវាខិតមកជិតអ្នកកាន់តែខ្លាំង។

### ខេត្តហ្វុគុអុកា «សារមន្ទីរវិទ្យាសាស្ត្រទីក្រុងហ្វុគុអុកា»

ដោយការរួមបញ្ចូលគ្នានូវបច្ចេកវិទ្យាអុបទិក និងឌីជីថល ឧបករណ៍បញ្ចាំងផ្កាយរណប របស់សារមន្ទីរនេះ ដែលជាឧបករណ៍ទំនើបបំផុតនៅលើពិភពលោក បញ្ចាំងផ្ទៃមេឃដែលមានផ្កាយដ៏អស្ចារ្យនៅលើអេក្រង់រាងក្រឡូម ដ៏ធំដែលមានអង្កត់ផ្ចិត២៥ម៉ែត្រ។ សារមន្ទីរនេះត្រូវបានជ្រើសរើសជាទីកន្លែងសម្រាប់សន្និសីទរបស់សមាគមន៍លំហរវិថីតារាសិប្បនិម្មិតអន្តរជាតិឆ្នាំ២០២៦ ដែលទទួលបានការចាប់អារម្មណ៍ទូទាំងពិភពលោក។ *(រូបថត៖ សារមន្ទីរវិទ្យាសាស្ត្រទីក្រុងហ្វុគុអុកា)*

<u>ទំព័រទី១៧៖</u>

### ខេត្តហុកកៃដូ «សារមន្ទីរវិទ្យាសាស្ត្រអាស៊ិការ៉ា SCI-PAL»

ការតាំងបង្ហាញឧបករណ៍ពិសោធន៍ជាក់ស្តែងជាច្រើននៅ SCI-PAL រួមមាន អ៊ុជឺ ហ្គូម៉ា (Uchu-goma) (មានក្នុងរូបភាព) ដែលអនុញ្ញាតឱ្យភ្ញៀវទទួលបានបទពិសោធន៍ក្នុងលំហ និង ម៉ូនចាំ(Moon Jump) ដែលត្រាប់តាមទំនាញផែនដីរបស់ផ្ទៃឋានព្រះចន្ទ។ សូមទស្សនាសារមន្ទីរនេះ ដើម្បីទទួលបានបទពិសោធន៍ផ្ទាល់ពីអារម្មណ៍នៃការក្លាយជាអវកាសយានិក។ *(រូបថត៖ សារមន្ទីរវិទ្យាសាស្ត្រអាស៊ិការ៉ា SCI-PAL)*

### ខេត្តអ៊ិបារ៉ាគិ «JAXA មជ្ឈមណ្ឌលអវកាសស៊ុគុបា»

បង្កើតឡើងក្នុងឆ្នាំ១៩៧២ គឺជាមជ្ឈមណ្ឌលស្នូលរបស់ JAXA ដែលជាកម្មវិធីអវកាសរបស់ប្រទេសជប៉ុន។ តំបន់ដ៏ធំល្វឹងល្វើយដែលមានទំហំប្រហែល៥៣០,០០០ម៉ែត្រការ៉េ គឺជាទីតាំងប្រមូលផ្តុំនៃគ្រឿងបរិក្ខារដែលអភិវឌ្ឍន៍ និងប្រតិបត្តិការរ៉ុក្កែត និងផ្កាយរណប។ ភ្ញៀវអាចទស្សនាគំរូដើមនៃរ៉ុក្កែតH-II ដែលត្រូវបានអភិវឌ្ឍ និងសាងសង់នៅក្នុងប្រទេសជប៉ុន (មានក្នុងរូបភាព) ក៏ដូចជាគំរូពេញលេញនៃផ្កាយរណបស្វែងយល់ពីឋានព្រះចន្ទដំបូងរបស់ជប៉ុនគឺ កាហ៊្គុយ៉ា(SELENE, Selenological and Engineering Explorer)។ *(© JAXA)*

**ទីក្រុងតូក្យូ «មជ្ឈមណ្ឌលស្រាវជ្រាវតារាសាស្ត្រជាតិរបស់ជប៉ុន នៅមិតាកាខេមភើស»**

វិទ្យាស្ថានស្រាវជ្រាវនេះ គឺជាបេះដូងនៃការស្រាវជ្រាវតារាសាស្ត្ររបស់ប្រទេសជប៉ុន ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៨៨ និងបានផ្លាស់ប្តូរទីតាំងមកកាន់ក្រុងមិតាកា ក្នុងឆ្នាំ១៩២៤។ ភ្ញៀវអាចទស្សនាកន្លែងស្រាវជ្រាវប្រវត្តិសាស្ត្រដែលស្ថិតនៅជុំវិញបរិវេណនោះ។ ចំណុចលេចធ្លោមួយគឺ តេឡេស្កុបឆ្លុះ ដែលមានជំរៅ៦៥សង់ទីម៉ែត្រ ដែលបានដំឡើងនៅសារមន្ទីរប្រវត្តិសាស្ត្រស្រាវជ្រាវតារាសាស្ត្រនេះ។ វា គឺជាតេឡេស្កុបឆ្លុះ ដ៏ធំបំផុតនៅក្នុងប្រទេសជប៉ុនរហូតមកដល់សព្វថ្ងៃនេះ។ *(រូបថត៖ មណ្ឌលស្រាវជ្រាវតារាសាស្ត្រជាតិរបស់ជប៉ុន)*

**ទីក្រុងតូក្យូ «វិទ្យាស្ថានបច្ចេកវិទ្យាឈិបា នៅប៉មតូក្យូស្កាយស្រ៊ី ថោន ខេមភើស»**

នៅជាន់ទី៨ នៃអគារ សូឡាម៉ាឈិ នៅប៉មតូក្យូស្កាយស្រ៊ី ដែលមានកម្ពស់៦៣៤ម៉ែត្រ គឺជាមជ្ឈមណ្ឌលសិក្សាអំពីមនុស្សយន្តកម្រិតខ្ពស់ និងអវកាស។ គ្រឿងបរិក្ខារដែលមានទំនាក់ទំនងគ្នានេះត្រូវបានបើកឱ្យសាធារណជនចូលទស្សនា ដើម្បីរីករាយនឹងការសិក្សាអំពីបច្ចេកវិទ្យាទំនើប និងលទ្ធផលស្រាវជ្រាវ។ រូបភាពនេះ គឺជារូបគំរូពេញលេញរបស់យានហាយ៉ាប៊ុសា២ (Hayabusa2) ដែលត្រូវបានដាក់តាំងបង្ហាញ។ *(រូបថត៖ វិទ្យាស្ថានបច្ចេកវិទ្យាឈិបា នៅប៉មតូក្យូស្កាយស្រ៊ី ថោន ខេមភើស)*

**ខេត្តអ៊ិស៊ិកាវ៉ា «សារមន្ទីរវិទ្យាសាស្ត្រអវកាស កុស៊ុម៉ុ អាអ៊ិរុ ហ៉ាគុអ៊ិ»**

សូមចូលទៅខាងក្នុងសារមន្ទីរដែលមានរាងដូចថាសហោះ ដ៏ប្លែកភ្នែក ដើម្បីទស្សនាយានអវកាស និងយានរុករកជាច្រើន ដែលបានវិលត្រឡប់មកពីអវកាស។ ក្នុងចំណោមនោះ អ្នកមិនគួររំលង LE-5 ដែលជាម៉ាស៊ីនដំបូងរបស់ជប៉ុនប្រើក្នុងការបាញ់បង្ហោះរ៉ុក្កែតទេ។ *(រូបថត៖ សារមន្ទីរវិទ្យាសាស្ត្រអវកាស កុស៊ុម៉ុ អាអ៊ិរុ ហ៉ាគុអ៊ិ)*

**ខេត្តហ្គិហ្វុ «សារមន្ទីរវិទ្យាសាស្ត្រអវកាស ហ៊ិដា កាមិអុកាវ៉ាបុ»**

ណឺទ្រីណូស គឺជាភាគល្អិតនៃអាតូមតូចៗ ដែលតូចជាងអាតូម ពេលធ្វើដំណើរឆ្លងកាត់លំហ។ គំរូជញ្ជាំងដ៏ធំនៃ ស៊ុប៉ាកាមិអុកានដិ (Super-Kamiokande) ត្រូវបានចម្លងយ៉ាងពិតជាក់ស្តែងនៅទីនេះដោយប្រើសម្ភារៈដូចគ្នានឹងឧបករណ៍ចាប់សញ្ញាពិតៗដែរ។ វា គឺជាទិដ្ឋភាពដ៏អស្ចារ្យដែលគួរតែទៅទស្សនា។*(រូបភាព៖ សារមន្ទីរវិទ្យាសាស្ត្រអវកាស ហ៊ិដា កាមិអុកាវ៉ាបុ)*

<u>ទំព័រទី១៨៖</u>

**រសជាតិជប៉ុន៖ ពេលដែលត្រូវទទួលទាន!**

## អាហារអវកាសជប៉ុន

រសជាតិដូចម្ហូបនៅផ្ទះ ក្នុងលំហអវកាស

*អវកាសយានិកជប៉ុន លោកយ៉ូអ៊ិ គិមិយ៉ា កំពុងរីករាយទទួលទាន មីរ៉ាមេនរសជាតិទឹកស៊ីអ៊ីវ ដែលត្រូវបានផលិតឡើងដើម្បីងាយស្រួលទទួលទានក្នុងបរិយាកាសទំនាញតិច (រូបខាងស្តាំ)។*

*ត្រីកំប៉ុង នេះត្រូវបានផលិតឡើងដោយប្រើត្រីសាបាមកពីខេត្តហ្វុគុអ៊ិ។ វាត្រូវបានផ្សំរសជាតិជាមួយទឹកស៊ីអ៊ីវ និងមានសាច់ទន់។*

អាហារអវកាស គឺជាអ្វីដែលមិនអាចខ្វះបានសម្រាប់ការរស់រានមានជីវិតនៅក្នុងអវកាស។ កាលពីអំឡុងទសវត្សរ៍ ឆ្នាំ១៩៦០ ដែលជាការចាប់ផ្តើមដំបូងនៃការហោះហើររបស់អ្នកអវកាស អាហារអវកាសមានតែអាហាររឹង និងអាហាររាវក្នុងបំពង់ប៉ុណ្ណោះ ហើយការវាយតម្លៃរសជាតិមិនសូវល្អទេឡើយ។ តែរយៈពេលជាងកន្លះសតវត្សរ៍ក្រោយមក អាហារអវកាសបានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងខ្លាំង។

ស្ថានីយ៍អវកាសអន្តរជាតិ (ISS) ដែលមានប្រទេសចំនួន១៥ ចូលរួមចាប់តាំងពីឆ្នាំ១៩៩៨ បានរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍនេះ។ ជីវភាពអាហារនៅលើយានត្រូវបានរៀបចំឡើងដោយយក «អាហារស្តង់ដារ» ដែលផ្គត់ផ្គង់ដោយសហរដ្ឋអាមេរិក និងរុស្ស៊ីជាចម្បង រួមជាមួយ "អាហារបន្ថែម" ដែលអវកាសយានិកអាចយកអាហារពីប្រទេសខ្លួនមកជាមួយ។

ចំពោះអវកាសយានិកជនជាតិជប៉ុន ពួកគេជ្រើសរើសអាហារបន្ថែមគឺ «អាហារអវកាសជប៉ុន» ដែលត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនចំណីអាហារក្នុងស្រុក និងបានទទួលស្គាល់ដោយទីភ្នាក់ងាររុករកអវកាសជប៉ុន (JAXA)។ ក្រៅពីបំពេញតាមស្តង់ដារទទួលស្គាល់យ៉ាងតឹងរ៉ឹងដែលតម្រូវឱ្យមានគ្រឿងបរិក្ខារអនាម័យត្រឹមត្រូវ ការវេចខ្ចប់ និងវិធីចម្អិនដែលមិនបែក ឬ ខ្ចាតក្នុងបរិយាកាសទំនាញតិច រសជាតិឆ្ងាញ់ គឺជាតម្រូវការចាំបាច់ផងដែរ។

ប្រទេសជប៉ុនដែលមានបច្ចេកវិទ្យាកែច្នៃអាហារ និងគុណភាពអនាម័យខ្ពស់តាំងពីដើមមក ដោយមានការចូលរួមពីក្រុមហ៊ុនចំណីអាហារតាមតំបន់ផ្សេងៗ ចំនួនមុខម្ហូបដែលបានទទួលស្គាល់បានកើនឡើងដល់៥៦មុខ គិតត្រឹមខែមីនា ឆ្នាំ២០២៥។ ក្នុងចំណោមនោះក៏មាន ត្រីសាបាកំប៉ុង ដែលត្រូវបានបង្កើតឡើងដោយសិស្សវិទ្យាល័យមកពីខេត្តហ្វុគុអ៊ិ អស់រយៈពេល១៤ឆ្នាំផងដែរ។

ក្រុមហ៊ុនផលិតគ្រឿងបរិភោគកញ្ចប់របស់ជប៉ុន ដែលជាអ្នកបង្កើតមីកញ្ចប់ដំបូងគេបង្អស់លើពិភពលោកក្នុងឆ្នាំ១៩៥៨ បានបង្កើតមីរ៉ាមេនដែលមានស៊ុបខាប់ដើម្បីងាយស្រួលបរិភោគក្នុងបរិយាកាសទំនាញតិច និងមានសរសៃមីរាងជុំដែលមិនងាយរលាយក្រោយពេលត្រាំទឹកក្តៅ។ មួយវិញទៀត មាន់បំពង(ការ៉ាអាហ្គិ) ដែលជាមុខម្ហូបដ៏ពេញនិយមរបស់ហាងលក់ទំនិញជប៉ុន (កុនប៊ិនានស៊ុស្តូរ) ក៏ត្រូវបានផលិតឡើងដោយវិធី ហ្វ្រីសដ្រាយ(សម្ងួតត្រជាក់) ដើម្បីប្រែក្លាយទៅជាអាហារអវកាស ដែលរក្សាបាននូវភាពស្រួយឆ្ងាញ់របស់វា។

<u>ទំព័រទី១៩៖</u>

អាហារទាំងនេះ មានចាប់ពីអាហារចម្បង រហូតដល់អាហារបន្ទាប់បន្សំ មានបង្អែម និងភេសជ្ជៈ សុទ្ធតែឆ្លុះបញ្ចាំងពីវប្បធម៌អាហាររបស់ជប៉ុន។ លក្ខណៈពិសេសរបស់វា គឺភាគច្រើន ជាអាហារសាមញ្ញៗដែលប្រជាជននិយមបរិភោគនៅផ្ទះដូចជា ការីបាយអុនិហ្គិរី យ៉ាគិសុបា(មីឆា) និង សាច់ហាំប៊ឺហ្គ ជាដើម។

អាហារអវកាសជប៉ុនដែលនាំមកនូវសុខភាពល្អ និងឆ្ងាញ់ទាំងនេះ ផ្តល់នូវភាពធូរស្រាលមួយរយៈដល់ជីវិតរស់នៅដ៏តឹងតែងក្នុងលំហដ៏សែនឆ្ងាយពីផែនដី ហើយវាថែមទាំងមានប្រជាប្រិយភាពខ្លាំងចំពោះអវកាសយានិកបរទេសទៀតផង។

*មីឆាកញ្ចប់ «នីសស៊ីន យ៉ាគិសុបា យូ ហ្វេស អូ» គ្រាន់តែបន្ថែមទឹកក្តៅ វានឹងរួចរាល់សម្រាប់ទទួលទាន នៅពេលដែលវាបានស្រូបទឹកអស់។*

*«សុប៉េស៊ុ ការ៉ាអាហ្គិ គុន (មាន់បំពងអវកាស) ដែលជាអាហារល្បីប្រចាំហាងលក់ទំនិញជប៉ុន(កុនប៊ិនានស៊ុស្តូរ) ត្រូវបានផលិតដោយវិធីហ្វ្រីសដ្រាយ (សម្ងួតត្រជាក់) ដើម្បីរក្សាបាននូវភាពស្រួយឆ្ងាញ់របស់វា។*

*ប្រទេសជប៉ុនក៏បានបញ្ជូនផ្លែឈើ និងបន្លែទៅកាន់អវកាសផងដែរ។ ក្នុងរូបភាពនេះ គឺជាផ្លែប៉ោមជប៉ុន ដែលត្រូវបានដឹកជញ្ជូនទៅកាន់ ISS ដោយយានផ្គត់ផ្គង់គ្មានមនុស្សបើក កូណុតុរិ ៦ (KOUNOTORI 6)។*

<u>ទំព័រទី២០៖</u>

<u>ទំព័រទី២១៖</u>

## កោះនៅភាគខាងត្បូងដែលភ្ជាប់ទៅនឹងអវកាស

## ដើរកំសាន្តប្រទេសជប៉ុន៖ កោះតាណេហ្គាស៊ីម៉ា

សមុទ្រ និងមេឃដ៏ខៀវស្រងាត់លាតសន្ធឹងដល់ផុតកន្ទុយភ្នែក។ នៅលើកោះតាណេហ្គាស៊ីម៉ាដែលពោរពេញទៅដោយធម្មជាតិដ៏សំបូរបែប អ្នកអាចស្រមៃគិតដល់អវកាសដ៏ធំធេង។




*១. ការបាញ់បង្ហោះរ៉ុក្កែត H3 នៅមជ្ឈមណ្ឌលអវកាសតាណេហ្គាស៊ីម៉ា។ (©JAXA)*
*២. ទស្សនិកជនកំពុងទស្សនាការបាញ់បង្ហោះនៅក្នុងឧទ្យានស្រាវជ្រាវអិបិណុអិ (រូបថត៖ សមាគមទេសចរណ៍តាណេហ្គាស៊ីម៉ា)។*
*៣, ៤. នៅសារមន្ទីរវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអវកាស នៃមជ្ឈមណ្ឌលអវកាសតាណេហ្គាស៊ីម៉ា ភ្ញៀវទេសចរណ៍អាចរីករាយនឹងការសិក្សាអំពីប្រវត្តិសាស្ត្រនៃកម្មវិធីអវកាស និងបច្ចេកវិទ្យាចុងក្រោយបង្អស់។ សូមថតរូបនៅកន្លែងថតរូបរបស់សារមន្ទីរ ដែលមើលទៅដូចជាអ្នកកំពុងអណ្តែតក្នុងលំហនៅលើស្ថានីយ៍អវកាស។ (©JAXA)*
*៥. បាយការ៉ុក្កែត ដែលជាមុខម្ហូបពិសេសនៅក្នុងភោជនីយដ្ឋានជូហានយ៉ា នៃមជ្ឈមណ្ឌលអវកាសតាណេហ្គាស៊ីម៉ា។*

ទំព័រទី២២៖

*៦, ៧. តេបប៉ូម៉ាត្សឺរី (ពិធីបុណ្យកាំភ្លើងវែង) ប្រារព្ធឡើងដើម្បីអបអរសាទរការមកដល់នៃកាំភ្លើងវែងមកកាន់ប្រទេសជប៉ុន។ (រូបថត៖ សមាគមទេសចរណ៍តាណិហ្គាស៊ីម៉ា និង សមាគមអភិរក្សអាវុធកាំភ្លើងវែងតាណិហ្គាស៊ីម៉ា)។*
*៨, ៩. កន្ត្រៃតាណិបាសាមិ (Tanebasami) ត្រូវបានដាងដែកជំនាញធ្វើដោយដៃម្តងមួយៗ។ (រូបថត៖ សារមន្ទីរកាំភ្លើងវែង(តេបប៉ូកាន)*

កោះតាណិហ្គាស៊ីម៉ាស្ថិតនៅភាគខាងត្បូងនៃប្រជុំកោះជប៉ុន ស្ថិតនៅផ្នែរភាគខាងត្បូងនៃខេត្តកាហ្គោស៊ីម៉ា ដែលត្រូវធ្វើដំណើរដោយយន្តហោះពីអាកាសយានដ្ឋានកាហ្គោស៊ីម៉ាប្រហែល៤០នាទី។ បើជិះទូកល្បឿនលឿន នឹងទៅដល់ក្នុងរយៈពេលប្រហែល ១ម៉ោង ៣០នាទី។ កោះនេះមានអាកាសធាតុក្តៅ និងធម្មជាតិដ៏អស្ចារ្យ ហើយជាទីតាំងរបស់ «មជ្ឈមណ្ឌលអវកាសតាណិហ្គាស៊ីម៉ា» ដែលជាមូលដ្ឋានជួរមុខនៃការអភិវឌ្ឍអវកាសរបស់ជប៉ុន។

នៅថ្ងៃបាញ់បង្ហោះរ៉ុក្កែត មនុស្សជាច្រើនមកពីទូទាំងប្រទេសបានមកជួបជុំគ្នា ដើម្បីទស្សនារ៉ុក្កែតដែលហោះឡើងទៅលើមេឃអមដោយសំឡេងគ្រហឹម និងពន្លឺភ្លឺផ្លេកៗ ដោយមានសមុទ្រពណ៌ខៀវចាស់ជាផ្ទៃខាងក្រោយរបស់វា។ មានហេតុផលមួយដែលមូលដ្ឋានបង្ហោះរ៉ុក្កែត ត្រូវបានសាងសង់នៅភាគខាងត្បូងនៃប្រទេសជប៉ុន ដែលជាកន្លែងដ៏ស្រស់ស្អាតបំផុតនៅក្នុងពិភពលោក គឺនៅពេលបាញ់បង្ហោះរ៉ុក្កែតទៅទិសខាងកើត ថាមពលគីណេទិចនៃការបង្វិលរបស់ផែនដីត្រូវបានបន្ថែមទៅក្នុងល្បឿនរបស់គ្រាប់រ៉ុក្កែត។ ពីព្រោះទីតាំងដែលនៅជិតខ្សែអេក្វាទ័រ និងមានល្បឿនបង្វិលលឿន នឹងផ្តល់កម្លាំងខ្លាំងដល់គ្រាប់រ៉ុក្កែត។ ដូច្នេះ កោះតាណិហ្គាស៊ីម៉ាដែលមានទីតាំងនៅជិតខ្សែអេក្វាទ័រ (រយៈទទឹងខាងជើង៣០ដឺក្រេ) និងមានដីធំទូលាយ ត្រូវបានជ្រើសរើសជាច្រកចូលអវកាសរបស់ជប៉ុន។

ក្រឡេកមើលប្រវត្តិសាស្ត្រវិញ កោះតាណិហ្គាស៊ីម៉ាធ្លាប់បានលេចមុខនៅលើឆាកប្រវត្តិសាស្ត្រជប៉ុនម្តង។ នៅសតវត្សរ៍ទី១៦ កាំភ្លើងវែងត្រូវបាននាំចូលមកកោះនេះដោយជនជាតិព័រទុយហ្គាល់ ដែលបានមកដល់កោះនេះដោយចៃដន្យ ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សម័យសង្គ្រាមស៊ីវិលរបស់ជប៉ុន។ ដើម្បីរំលឹកដល់ព្រឹត្តិការណ៍នេះ «តេបប៉ូម៉ាត្សឺរី (ពិធីបុណ្យកាំភ្លើងវែង)» ដែលមានមនុស្សស្លៀកពាក់បែបប្រពៃណីនៅសម័យនោះធ្វើពិធីសាកល្បងបាញ់កាំភ្លើងវែងជាដើម ដែលពិធីបុណ្យនេះនៅតែត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំរហូតមកដល់បច្ចុប្បន្ន។

*១០. ដំឡូងផ្វា អានណូ អ៊ីម៉ូ ដែលមានជាតិផ្អែមខ្លាំង និងមានសាច់ស្អិត មានរសជាតិឆ្ងាញ់។ (រូបភាព៖ PIXTA)*
*១១. ការ៉េមជេឡាតូ (Gelato) ធ្វើពីដំឡូងផ្វា អានណូ អ៊ីម៉ូ ពីហាងការ៉េម តាណិហ្គាស៊ីម៉ា ជេឡាតូ HOPE។*
*១២. នំផាយ ស្នូលដំឡូង អានណូ អ៊ីម៉ុ ពីហាងនំ សាកាអ៊ិយ៉ា។*

ទំព័រទី២៣៖

*១៣. ការជិះទូកកាយ៉ាក់រុករកក្នុងរុងព្រៃកោងកាង គឺជាសកម្មភាពដ៏ពេញនិយមបំផុតមួយនៅលើកោះតាណិហ្គាស៊ីម៉ា។ (រូបភាព៖ BLUE PEACE តាណិហ្គាស៊ិម៉ា)*
*១៤. ឈិគុរ៉ា ណុ អ៊ិវ៉ាយ៉ា ដែលជាល្អាងសមុទ្រធំជាងគេបំផុតនៅលើកោះតាណិហ្គាស៊ីម៉ា ត្រូវបានបង្កើតឡើងដោយការហូរច្រោះពីទឹករលកខ្លាំងៗនៃមហាសមុទ្រប៉ាស៊ីហ្វិក។ (រូបភាព៖ PIXTA)*

*១៥. មុជទឹកចូលទៅក្នុងទឹកសមុទ្រពាក់ដ៏ស្រស់ស្អាត ដើម្បីមើលត្រីដែលអ្នកអាចឃើញមានតែនៅក្នុងតំបន់ត្រូពិច។ (រូបភាព៖ Dive Award)*

«កន្ត្រៃតាណិបាសាមិ(Tanebasami)» ដែលត្រូវបាននាំចូលមកជាមួយកាំភ្លើងវែង គឺជាកន្ត្រៃដែលមានចំណុចទ្រទម្ងន់នៅចន្លោះចំណុចចាប់កាន់ និងមុខកាំបិត។ ដោយសារតែមុខកាំបិតមុតស្រួច និងភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់ទាំងអ្នកប្រើដៃស្តាំ និងដៃឆ្វេង មិនយូរប៉ុន្មាន វាបានក្លាយជាសិប្បកម្មប្រពៃណីដ៏ល្បីល្បាញរបស់កោះតាណិហ្គាស៊ីម៉ា។ នៅសតវត្សរ៍ទី១៧ ដំឡូងជ្វា ដែលបានមកពីដីគោកត្រូវបានចាប់ផ្តើមដាំដុះនៅលើកោះ។ នាពេលថ្មីៗនេះ ដំឡូងជ្វាត្រូវបានកែច្នៃក្លាយទៅជាពូជដំឡូង «អានណូ អ៊ីម៉ុ» ដែលមានរសជាតិផ្អែមស្រទន់ និងសាច់ល្អិតល្អ ប្រើសម្រាប់ធ្វើនំផ្អែមដ៏សម្បូរបែប ហើយក្លាយជាអាហារល្បីប្រចាំតំបន់។

ប្រសិនបើអ្នកចង់រីករាយនៅកោះតាណិហ្គាស៊ីម៉ាឱ្យបានពេញលេញ សូមកុំភ្លេចផ្តោតលើធម្មជាតិដ៏អស្ចារ្យរបស់វាផងដែរ។ វាជាកន្លែងរស់នៅរបស់រុក្ខជាតិត្រូពិចកម្រ ដែលមិនសូវមាននៅក្នុងប្រទេសជប៉ុន និងព្រៃកោងកាងលាតសន្ធឹងនៅតាមបណ្តោយទន្លេជាច្រើន។ អ្នកអាចជិះទូកកាយ៉ាក់តាមដងព្រែក ដើម្បីទទួលយកភាពស្រស់ស្អាតនៃព្រៃធម្មជាតិ។ លើសពីនេះ តាមបណ្តោយឆ្នេរ មានតំបន់ថ្ម ដែលបានបង្កើតឡើងដោយការហូរច្រោះរបស់រលក ហើយវាស៊ីគ្នាជាមួយសមុទ្រពណ៌មរកត បង្កើតបានជាទេសភាពដ៏ស្រស់ស្អាត។ វាជាកន្លែងដ៏អស្ចារ្យ និងរីករាយ សម្រាប់កីឡាក្នុងសមុទ្រ។ នៅពេលអ្នក ជ្រមុជទឹកចូលទៅក្នុងសមុទ្រ អ្នកនឹងជាប់ចិត្តទៅដោយពិភពដ៏ស្រស់ស្អាតដែលតុបតែងដោយត្រីត្រូពិចចម្រុះពណ៌ និងផ្កាថ្ម។

នៅលើកោះនេះ លាតសន្ធឹងធំធេងទៅដល់ផ្ទៃមេឃ និងសមុទ្រ ដែលអ្នកអាចរីករាយនឹងបណ្តោយខ្លួនអ្នកទៅតាមលំហូរពេលវេលាដ៏ធំទូលាយ ហើយគិតដល់ពរជ័យនៃធម្មជាតិ និងអវកាស។

***ផែនទីតំបន់តាណិហ្គាស៊ីម៉ា***

*១ JAXA មជ្ឈមណ្ឌលអវកាសតាណិហ្គាស៊ីម៉ា*
*២ ឧទ្យានស្រាវជ្រាវអិបិណ្ណអិ*
*៣ ហាងការ៉េម តាណិហ្គាស៊ីម៉ា ដេឡាតូ HOPE*
*៤ ហាងនំ សាកាអ៊ិយ៉ា*
*៥ ឈិគុរ៉ា ណុ អ៊ិវ៉ាយ៉ា*

- ***មធ្យោបាយធ្វើដំណើរ***
  *ចំណាយពេលប្រហែល៤០នាទី ពីអាកាសយានដ្ឋាន កាហ្គោស៊ីម៉ា ឆ្ពោះទៅកាន់ អាកាសយានដ្ឋាន តាណិហ្គាស៊ីម៉ា ដោយយន្តហោះ។*
  *ចំណាយពេលប្រហែល៩០នាទី ពីកំពង់ផែកាហ្គោស៊ីម៉ា Main Port South Wharf ទៅកំពង់ផែ និស៊ិណូអុម៉ុតិ ដោយទូកល្បឿនលឿន។*
- ***ទំនាក់ទំនងពត៌មាន***
  *គេហទំព័រផ្លូវការនៃការិយាល័យសមាគមទេសចរណ៍តាណិហ្គាស៊ីម៉ា*
  *「#tanetabi」*
  *https://tanekan.jp/*

<u>ទំព័រទី២៤៖</u>

## វត្ថុអនុស្សាវរីយ៍របស់ជប៉ុន㉙៖ សម្ភារៈការិយាល័យបែបអវកាស

### ពិភពលោកគ្មានដែនកំណត់លើតុរបស់អ្នក

*១. មេដែក ឬ ដែកឆក់ 3D ដែលបង្ហាញពីភពផែនដី ព្រះចន្ទ ភពព្រហស្បតិ៍ ភពសៅរ៍ និងភពផ្សេងៗទៀតដែលត្រូវបានគ្របដោយកញ្ចក់។ (រូបថត៖ LUSTERX., INC. )*
*២. ឈុតស្រោមសំបុត្រ ដែលមានស្រោមសំបុត្ររូបផ្ទៃមេឃមានផ្កាយ ពេលដាក់ចូលក្នុងឈុតស្រោមសំបុត្រដែលមានបង្អួច (អាចមើលឃើញសំបុត្រនោះ)។ (រូបថត៖ Vixen Co., Ltd. )*
*៣. ប្រដាប់កិប ដែលយកគំរូតាមយានអវកាសដែលមានរ៉ុក្កែតអាចដកចេញបាន។ (រូបថត៖ Seto Craft Co., Ltd. )*
*៤. ស្កុតបិត របស់ជប៉ុនដែលតុបតែងដោយរូបផ្ទៃមេឃពេញដោយផ្កាយ និងព្រះចន្ទ។ (រូបថត៖ LALA CloveR. )*
*៥. ប៊ិកចុច រាងដូចទៅនឹងរ៉ុក្កែតH3។ (រូបថត៖ BCC Co., Ltd. )*

សម្ភារៈការិយាល័យដែលយកប្រធានបទអវកាស គឺជាអ្វីដែលអនុញ្ញាតឱ្យយើងរីករាយជាមួយនឹងមន្តស្នេហ៍នៃអវកាសដ៏មហិមានៅលើតុ។
ឧទាហរណ៍ថា ស្កុតបិត រូបផ្កាយ និងព្រះចន្ទ ពណ៌មាស និងប្រាក់ ដែលរាយប៉ាយ គឺជាវត្ថុដ៏អស្ចារ្យមួយដែលមានផ្ទៃមេឃពោរពេញដោយផ្កាយ រាល់ពេលដែលទាញចេញ។ វានឹងបន្ថែមភាពស្រស់ស្អាតដល់ការតុបតែងលិខិត ឬ សៀវភៅកំណត់ហេតុ។ ឈុតស្រោមសំបុត្រ ដែលមានសំបុត្ររូបផ្ទៃមេឃពោរពេញដោយផ្កាយមានការរចនាដូចជាកំពុងមើលតារាសាស្ត្រ នៅពេលដែលសំបុត្រត្រូវបានដាក់ចូលក្នុងឈុតស្រោមសំបុត្រ។ ប្រាកដណាស់ អ្នកទទួលសំបុត្រនឹងចង់ក្រោកមើលផ្ទៃមេឃពេលយប់។ម្យ៉ាងវិញទៀត បើដាក់ដែកឆក់រូបភពនានាតាមចំណង់ចំណូលចិត្តអ្នក នៅលើទូទឹកកក ឬ ក្ដារខៀនពណ៌ស នោះពិភពផ្ទាល់ខ្លួនរបស់អ្នក នឹងត្រូវបានបង្កើតឡើង។
សម្ភារៈការិយាល័យមួយមុខទៀតដែលមានប្រធានបទរុករកអវកាស គឺ ប៊ិកចុច ដែលយកគំរូតាមរ៉ុក្កែតដ៏ធំ H3 របស់ជប៉ុន ហើយមានរូបតុក្កតាតំណាងឱ្យយានផ្គត់ផ្គង់ស្ថានីយអវកាសថ្មី(HTV-X) ដែលកំពុងស្ថិតនៅក្រោមការអភិវឌ្ឍ ព្យួរនៅចុងម្ខាងនៃប៊ិក។ ដូចគ្នានេះដែរ ប្រដាប់កិបក្រដាស រាងយានអវកាសដែលដាក់នៅលើតុរបស់អ្នកក៏នឹងជម្រុញទឹកចិត្តអ្នកឱ្យដោះស្រាយការងារជាច្រើន បានយ៉ាងសកម្មផងដែរ។
សូមប្រមូលសម្ភារៈការិយាល័យដែលមានប្រធានបទអវកាស ដើម្បីបន្ថែមភាពរីករាយទៅក្នុងមុខងារប្រើប្រាស់ និងបង្កើតបរិយាកាសនៃការរុករកលំហអវកាសនៅលើតុរបស់អ្នក។

*ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣៨*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ីមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង https://www.mofa.go.jp/*
*គេហទំព័រដែលផ្ដល់ព័ត៌មានអំពីជប៉ុន https://web-japan.org/*

**សម្រាប់សំណៅបកប្រែភាសាខ្មែរផ្សេងទៀត អាចចូលអានបាន តាមលីង ឬ QR Code ខាងក្រោមនេះ៖**
https://www.kh.emb-japan.go.jp/itpr_ja/11_000001_00654.html